ក្រសួងពាណិជ្ជកម្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថាស្វាគមន៍

**របស់ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ក្នុងកម្មវិធីបើកសន្និបាតបូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ ២០០៩**
**និងលើកទិសដៅការងារពាណិជ្ជកម្មឆ្នាំ ២០១០**
**រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១០**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ជាទីគោរព !**
- **អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ជាទីមេត្រី !**

ថ្ងៃនេះ ជាថ្ងៃដ៏ល្អប្រពៃ ដែលថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម បានជួបជុំគ្នារៀបចំធ្វើសន្និបាតប្រចាំឆ្នាំដើម្បីបូកសរុបការងារពាណិជ្ជកម្ម ឆ្នាំ ២០០៩ និងកំណត់ទិសដៅការងារ ពាណិជ្ជកម្មសំរាប់ឆ្នាំ ២០១០ និង ឆ្នាំបន្តទៀត នាអគារទីស្តីការក្រសួងពាណិជ្ជកម្មថ្មី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**។

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងពាណិជ្ជកម្មទាំងអស់ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតឱកាសដ៏មមាញឹក អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកសន្និបាតប្រចាំឆ្នាំរបស់ក្រសួងពាណិជ្ជកម្ម ។

ខ្ញុំបាទសូមអនុញ្ញាតជំរាបថា ក្នុងសន្និបាតនេះ មានមន្ត្រីពាណិជ្ជកម្ម ថ្នាក់ការិយាល័យ ថ្នាក់មន្ទីពាណិជ្ជកម្មខេត្ត-រាជធានី ថ្នាក់នាយកដ្ឋាន ថ្នាក់អគ្គនាយកដ្ឋាន ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម តំណាង-ក្រសួងពាក់ពន្ធ័នានា និងតំណាងវិសយ័ឯកជន ចូលរួមដែលសរុបទាំងអស់មានប្រមាណ ៣០០ នាក់។

អង្គសន្និបាតនេះ នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៤ ដល់ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ ដូចមានក្នុងកម្មវិធីចែកជូនស្រាប់ហើយរបាយការណ៍ស្តីពីសមិទ្ធផលពាណិជ្ជកម្ម ឆ្នាំ ២០០៩ និងទិសដៅពាណិជ្ជកម្ម ឆ្នាំ ២០១០

ក៏បានចែកជូនផងដែរ ។ ក៏ប៉ុន្តែខ្ញុំយល់ថារបាយការណ៍នេះ មិនទាន់មានភាពសុក្រិតទាំងស្រុងនោះទេ ដូចនេះ សូមឯកឧត្តម អស់លោក លោកស្រីទាំងអស់ មេត្តាជួយពិនិត្យ និងបំពេញបន្ថែមនូវចំណុចខ្វះខាតដែលអាចមាន ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី**

នាឆ្នាំ ២០០៩ កន្លងទៅនេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** រួមជាមួយនឹងការខិតខំប្រឹងប្រែងដ៏ខ្លាំងក្លា និងមោះមុតរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ ក្រសួងពាណិជ្ជកម្មបានបំពេញនូវកិច្ចការសំខាន់ៗ ជាច្រើន ដែលរាជរដ្ឋាភិបាលបានប្រគល់ ជូនប្រកបដោយជោគជ័យ ក្នុងនោះមានៈ

- ការងារផ្តល់សេវាសាធារណៈជូនវិស័យឯកជន និងសាធារណៈជន ដែលរួមមាន : ការចុះបញ្ជីក្រុមហ៊ុនអាជីវកម្ម ការចុះបញ្ជីពាណិជ្ជសញ្ញា ការផ្តល់វិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ ការត្រួតពិនិត្យគុណភាពទំនិញ ជាពិសេសផលិតផលម្ហូបអាហារនាំចេញ-នាំចូល និងម្ហូបអាហារដែលដាក់លក់នៅលើទីផ្សារក្នុងស្រុក ។ ជារួម ក្នុងការផ្តល់នូវសេវាសាធារណៈ ទាំងនោះក្រសួងពាណិជ្ជកម្ម បានចូលរួមប្រមូលចំណូលជាច្រើនបង់ចូលថវិការរដ្ឋ ។ សំរាប់ ឆ្នាំ ២០០៩ ក្រសួងពាណិជ្ជកម្ម ប្រមូលចំណូលបានចំនួន ១២៩,៩៤៩ លានរៀល ឬ ស្មើនឹង ១១១,៦ ភាគរយ នៃផែនការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ ។

- ការតាមដាន និងទប់ស្កាត់ នូវការឡើងថ្លៃទំនិញប្រើប្រាស់ជាមូលដ្ឋានសំខាន់ៗ ដោយពុំសមហេតុផល ដូចជា ម្ហូបអាហារ និងប្រេងឥន្ធនៈ ។ល។ ជារួម យើងសង្កេតឃើញថា តំលៃទំនិញប្រើប្រាស់ជាមូលដ្ឋានសំខាន់ៗ ក្នុងឆ្នាំ ២០០៩ មានស្ថេរភាពល្អ ហើយអត្រា អតិផរណាប្រចាំឆ្នាំ ២០០៩ មានត្រឹមតែ ៥,៣ ភាគរយប៉ុណ្ណោះ នៅពេលដែលអត្រាអតិផរណាប្រចាំឆ្នាំ ២០០៨ មានរហូតដល់ទៅ ១២,៥ ភាគរយ ។

- ការកសាងច្បាប់ និងបទបញ្ញត្តិពាណិជ្ជកម្ម ដើម្បីឱ្យយន្តការសេដ្ឋកិច្ចទីផ្សារដំណើរការបានល្អ ហើយជួយសំរួលដល់អាជីវករ និងអ្នកវិនិយោគ ឱ្យពួកគេមានការកក់ក្តៅក្នុងការធ្វើអាជីវកម្ម និងធានានូវការប្រកួតប្រជែងដ៏ត្រឹមត្រូវ ។

- ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មជាទ្វេភាគី ជាអនុតំបន់ ជាមួយប្រទេសជិតខាង ជាមួយប្រទេសក្នុងតំបន់អាស៊ាន និងពិភពលោក រួមទាំង បន្តការចរចាបើកទីផ្សារអន្តរជាតិសំរាប់ផលិតផលកម្ពុជា ។

- ការស្វែងរក និងប្រើប្រាស់ជំនួយបច្ចេកទេស ដើម្បីកសាងនិងពង្រឹងសមត្ថភាពផ្នែក ពាណិជ្ជកម្ម និងការនាំចេញ ក៏ដូចជាជួយពង្រឹងសមត្ថភាពក្រសួងស្ថាប័នពាក់ពន្ធ័នឹង ពាណិជ្ជកម្ម ផងដែរ និង
- ការសំរួល និងជំរុញពាណិជ្ជកម្ម តាមរយៈការរៀបចំ និងចូលរួមពិពណ៌ពាណិជ្ជកម្ម នៅក្នុង និងក្រៅប្រទេស ការផ្តល់ពត៌មានពីតំលៃកសិផលសំខាន់ៗ ការលើកទឹកចិត្តផលិតករ ម្ចាស់ម៉ាស៊ីនកិនស្រូវ ឬ អ្នកនាំចេញ ឱ្យបង្កើតសមាគម ។ល។

យោងតាមស្ថិតិរបស់ធនាគារជាតិនៃកម្ពុជា ពាណិជ្ជកម្មនាំចេញ-នាំចូលនៅឆ្នាំ ២០០៨ បាន កើនឡើងចំនួន ១៦,៧ % គឺពី ៩,៦ ពាន់លានដុល្លា នៅឆ្នាំ ២០០៧ ទៅ ១១,២ ពាន់លានដុល្លានៅឆ្នាំ ២០០៨។ ក៏ប៉ុន្តែ នៅឆ្នាំ ២០០៩ ដោយសារវិបត្តិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសកលលោក ពាណិជ្ជកម្ម ក្រៅប្រទេសរបស់កម្ពុជា ក៏ដូចជាប្រទេសជាច្រើនក្នុងពិភពលោក បានធ្លាក់ចុះចំនួន ១០,៤% មកនៅត្រឹម ១០ ពាន់លានដុល្លា។ ក្នុងនេះ ការនាំចេញតាមប្រពន្ធ័អនុគ្រោះពាណិជ្ជកម្ម បានធ្លាក់ចុះ ចំនួន ១៥,៤៦% គឺពី ៣,២ ពាន់លានដុល្លា មកនៅត្រឹម ២,៧ ពាន់លានដុល្លា នៅឆ្នាំ ២០០៩ នៅពេលដែលការនាំចេញនៅឆ្នាំ ២០០៨ មានកំណើន ២%។ ដោយសារការធ្លាក់ចុះនៃការនាំចេញតាមប្រពន្ធ័អនុគ្រោះពាណិជ្ជកម្មនេះ និងឥទ្ធិពលនៃកត្តាផ្សេងៗទៀត ដូចជា ទេសចរណ៍ និងការសាងសង់ ។ល។ កំណើនសេដ្ឋកិច្ចកម្ពុជា បានថយចុះពីកំណើន ៦,៨% នៅឆ្នាំ ២០០៨ មកកំណើននៅត្រឹម ២% នៅឆ្នាំ ២០០៩ បើយោងតាមស្ថិតិរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះជាយ៉ាងនេះក៏ដោយ យើងឃើញថា សេដ្ឋកិច្ចរបស់កម្ពុជា នៅតែមានសក្តានុពល ដែលជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី**

ដើម្បីរួមចំណែកអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងជាពិសេសការបន្តជំរុញអនុវត្តយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាព របស់ប្រជាពលរដ្ឋ កិច្ចប្រជុំក្នុងរយះពេលបីថ្ងៃខាងមុខនេះ នឹងផ្តោតការពិភាក្សា ដោះដូរយោបល់លើ ចំណុចសំខាន់ៗ ដូចខាងក្រោម ដើម្បីឱ្យក្រសួងពាណិជ្ជកម្មអាចបន្តអនុវត្តប្រកបដោយជោគជ័យនូវ គោលដៅខាងលើនេះ:

១-ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ
២-បន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងសហគមន៍អន្តរជាតិ និងបន្តបើកច្រកទីផ្សារទាំងនោះ ឱ្យ ផលិតផលកម្ពុជា បានចូលទៅកាន់ទីផ្សារដ៏ធំធេងក្នុងពិភពលោកដោយងាយស្រួល
៣-ការគ្រប់គ្រងថ្លៃទំនិញប្រើប្រាស់ជាមូលដ្ឋានសំខាន់ៗ ដូចជាម្ហូបអាហារ និងប្រេងឥន្ទនៈ

៤-ការធ្វើពិពិធភាវូបនីយកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ផលិតផលកម្ពុជា
៥-ការចូលរួមធ្វើឱ្យតម្លៃនៃការធ្វើធុរៈកិច្ចថយចុះ
៦-ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ រដ្ឋបាលតែមួយ និងសេវាច្រកចេញចូលតែមួយ
៧-បន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត សម្រាប់គាំទ្រវិស័យឯកជនរួមមានបទបញ្ញត្តិច្បាប់ និង នីតិវិធីរដ្ឋបាល
៨-បន្តជំរុញកិច្ចសំរួលពាណិជ្ជកម្ម
៩-បន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌការងារ រោងចក្រល្អប្រសើរ និង
១០-បង្កើនការគ្រប់គ្រង រៀបចំយុទ្ធសាស្ត្រ វិភាគនិងអនុវត្តនគោលនយោបាយពាណិជ្ជកម្មក្នុងស្រុក និង ក្រៅប្រទេស អភិវឌ្ឍន៍ទីផ្សារចាស់ និងស្វែងរកទីផ្សារថ្មីៗ ។

ជាថ្មីម្តងទៀតតាងនាមឱ្យថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងពាណិជ្ជកម្ម និងក្នុងនាមខ្ញុំបាទផ្ទាល់ ខ្ញុំសូមសំដែងនូវអំណរអរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងសូមប្រសិទ្ធិពរជូន **ឯកឧត្តម ព្រាមនាំងគ្រួសារ** ទទួលបាននូវសិរីសួស្តី វិបុលសុខបវរមហាប្រសើរ សុខភាព មាំមួន ប្រាជ្ញាឈ្លៀសវៃ ដើម្បីបន្តចូលរួមដឹកនាំព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅកាន់វឌ្ឍនភាពដ៏ត្រចះត្រចង់ ។

សូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា ភ្ញៀវកិត្តិយស និងមន្ត្រីរាជការទាំងអស់ នូវពុទ្ធពរ ទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ** និង **ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ជាកិច្ចចាប់ផ្តើមអង្គសន្និបាត ខ្ញុំបាទសូមគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** អញ្ជើញមានមតិសំណេះសំណាល និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ប្រកបដោយបទពិសោធន៍ល្អៗ ដើម្បីឱ្យយើងខ្ញុំបានបង្កើនការយល់ដឹង សំរាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ជាបន្តទៅថ្ងៃអនាគត ។

**សូមគោរពអញ្ជើញ !!**